01456719

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / 05 / 2017
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E319/35/12

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧

**ផ្ញើជូន៖** **គ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២/០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/ចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំលុបចោលលក្ខខណ្ឌកោសលុប និងប្រើប្រាស់រហស្សនាមសម្រាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២**

1. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើមួយ ដែលបានដាក់ដោយសហព្រះរាជអាជ្ញាកាលពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៧ ដោយបានស្នើសុំឱ្យអង្គជំនុំជម្រះលុបចេញនូវលក្ខខណ្ឌកោសលុបប្រតិចារឹកក្នុងសំណុំរឿង ០០២/០២ ឬ ការប្រើប្រាស់រហស្សនាមសម្រាប់សាក្សីក្នុងសំណុំរឿង ០០២/០២ ជាបន្តទៀត។ សហព្រះរាជអាជ្ញាយល់ឃើញថា លែងមានភាពចាំបាច់ក្នុងការរក្សាលក្ខខណ្ឌខាងលើនេះទៀតហើយ ហើយអង្គជំនុំជម្រះគួរដាក់ប្រតិចារឹកទាំងអស់ក្នុងសំណុំរឿង ០០២/០២ ជាសាធារណៈ (ឯកសារ E319/35/7 កថាខណ្ឌ ៤) ("សំណើសុំរបស់ ក.ស.ព.")។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា វិធានការទាំងនេះត្រូវបានស្នើសុំដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ.) ហើយមានការយល់ព្រមពីអង្គជំនុំជម្រះសាលាដំបូងដើម្បីការពារអត្ត-សញ្ញាណរបស់សាក្សីដែលបានផ្តល់ភ័ស្តុតាងនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ផងដែរ (ឯកសារ E319/35/7 កថាខណ្ឌ ១)។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ប្រយោជន៍នៃការធ្វើសវនាការជាសាធារណៈតម្រូវថា សាធារណជនអាចយល់ដឹងអំពីខ្លឹមសារនៃសក្ខីកម្ម និងអត្ត-សញ្ញាណរបស់បុគ្គលដែលផ្តល់សក្ខីកម្ម តាមរយៈការអនុញ្ញាតឱ្យដាក់សារណាបញ្ចប់កិច្ចពិភាក្សា

ដេញដោល និងការយោងលើព័ត៌មានបែបនេះនៅក្នុងពេលធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល លើកលែងតែមានការបង្ហាញនូវការព្រួយបារម្ភអំពីសុវត្ថិភាពរបស់សាក្សី ឬ ការសម្ងាត់នៃការស៊ើបអង្កេតដែលកំពុងដំណើរការ (ឯកសារ E319/35/7 កថាខណ្ឌ ៣)។

2. កាលពីថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនសំណើរបស់ ក.ស.ព. បន្តជូនទៅ ស.ច.ស.អ. ដើម្បីសុំយោបល់ថា តើការសម្ងាត់នៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នៅតម្រូវឱ្យមានវិធានការទាំងនេះអនុវត្តចំពោះប្រតិចារឹក និងសាក្សីនៅក្នុងសំណុំរឿង ០០២/០២ ឬ ថាតើវិធានការទាំងនេះគួរលើកលែងនៅពេលនេះ ឬ ក៏យ៉ាងណា (ឯកសារ E319/35/8)។ ស.ច.ស.អ. បានឆ្លើយតបនៅថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៧ ដោយស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យការិយាល័យសហព្រះរាជអាជ្ញារៀបរាប់សាក្សី/សក្ខីកម្មណាខ្លះ ដែលសហព្រះរាជអាជ្ញាស្នើសុំឱ្យធ្វើការវាយតម្លៃឡើងវិញ (ឯកសារ E319/35/9.1)។ នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១៧ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជូនចម្លើយតបរបស់ ស.ច.ស.អ. បន្តជូនទៅសហព្រះរាជអាជ្ញាដោយបានអញ្ជើញសហព្រះរាជអាជ្ញាឱ្យដាក់ចម្លើយតបមកវិញ (ឯកសារ E319/35/9)។ សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបនៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៧ ដោយបានផ្ដល់ព័ត៌មានដែលបានស្នើសុំជូនអង្គជំនុំជម្រះ និង ស.ច.ស.អ. ហើយបានគូសបញ្ជាក់ឡើងវិញនូវសេចក្ដីសន្និដ្ឋានអំពីភាពចាំបាច់ត្រូវឱ្យមានដំណើរការជាសាធារណៈ និងប្រកបដោយតម្លាភាពតាមរយៈការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលជាសាធារណៈ (ឯកសារ E319/35/10)។ នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧ អង្គជំនុំជម្រះបានបញ្ជូនសេចក្ដីសន្និដ្ឋានទាំងនេះបន្តជូនទៅ ស.ច.ស.អ. ហើយបានស្នើសុំឱ្យដាក់ចម្លើយតបមកវិញយ៉ាងយូរត្រឹមថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១៧ ដើម្បីជូនជាព័ត៌មានដល់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E319/35/11)។ ដោយសារកំហុសរៀបចំចាត់ចែងសេចក្ដីជូនដំណឹង ស.ច.ស.អ. ទើបតែទទួលបានការជូនដំណឹងអំពីអនុស្សរណៈចុងក្រោយនេះនៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០១៧ ប៉ុណ្ណោះ។

3. ស.ច.ស.អ បានឆ្លើយតបមកវិញនៅថ្ងៃទី ២៤ ខែ មេសា ឆ្នាំ២០១៧ ដោយបានទទួលស្គាល់ថាខ្លួនបានទទួលសេចក្ដីសន្និដ្ឋានចំនួនពីររបស់ ក.ស.ព. (ឯកសារ E319/35/7 និងឯកសារ E319/35/10) ព្រមទាំងចង្អុលបញ្ជាក់ថា ស.ច.ស.អ. ពុំអាចមានលទ្ធភាពផ្ដល់អាទិភាពលើសំណើសុំរបស់ ក.ស.ព. នៅក្នុងរង្វង់ពេលវេលាដូចបានកំណត់ដោយអង្គជំនុំជម្រះសម្រាប់ដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនោះទេ ដោយសារភាពចាំបាច់ត្រូវផ្ដោតធនធានបុគ្គលិកមានកម្រិតរបស់ខ្លួនលើការងារចំបង ហើយបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទាមទារឱ្យភាគីគោរពតាមវិធានការនានាដែលបានអនុវត្តជាធរមាន (ឯកសារ E319/35/12.1)។

4. អង្គជំនុំជម្រះសូមរំលឹកឡើងវិញថា ខ្លួនបានចាត់វិធានការឲ្យគោរពតាមលក្ខខណ្ឌនានាដូចបានស្នើឡើងដោយ ស.ច.ស.អ. លើការដាក់បង្ហាញចម្លើយនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២ ដោយរួមបញ្ចូលការប្រើប្រាស់រហស្សនាមសម្រាប់សាក្សី ការស្ដាប់សក្ខីកម្មសាក្សីមួយចំនួនក្នុងសវនាការអសាធារណៈ និងការផ្សាយជាសាធារណៈនូវប្រតិចារឹកសវនាការទាំងនោះក្នុងទម្រង់កោសលុប (ឯកសារ E319/35/5)។ ទោះបីភាគីមានសិទ្ធិទទួលបានសវនាការជាសាធារណៈក៏ដោយ ក៏កិច្ចដំណើរការនីតិវិធីអាចដំណើរការទៅជាអសាធារណៈបានក្នុងករណីដែលសវនាការជាសាធារណៈនាំឲ្យមានផលប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឧទាហរណ៍ ការបង្កអន្តរាយលើការស៊ើបអង្កេតដែលកំពុងដំណើរការ (ឯកសារ E319/35/5 កថាខណ្ឌ ៤-៥)។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺជាការិយាល័យតែមួយគត់ដែលអាចវាយតម្លៃថាតើកត្តានានាដែលនាំដល់ការដាក់លក្ខខណ្ឌទាំងនោះមានការប្រែប្រួលហើយ ឬ នៅ និងជាពិសេសថាតើការដាក់បង្ហាញព័ត៌មានដែលស្ថិតក្រោមការការពារអាចនាំឲ្យមានផលប៉ះពាល់អវិជ្ជមានលើការសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងដំណើរការដែរ ឬ យ៉ាងណា (ឯកសារ E319/35/5 កថាខណ្ឌ ៥)។ អង្គជំនុំជម្រះពុំមានលទ្ធភាពលុបចោលលក្ខខណ្ឌនៃការកោសលុបប្រតិចារឹក ឬ អនុញ្ញាតឲ្យយោងលើឈ្មោះសាក្សីដែលស្ថិតក្រោមលក្ខខណ្ឌការពារតាមអំណាចដីកាបង្គាប់របស់ ស.ច.ស.អ. បានទេ រហូតទាល់តែ ស.ច.ស.អ. បញ្ជាក់ថា ការផ្សព្វផ្សាយព័ត៌មានទាំងនេះជាសាធារណៈលែងប៉ះពាល់ការសម្ងាត់នៃការស៊ើបសួរលើសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ទៀតហើយ។ យោងតាមសំអាងហេតុនេះ អង្គជំនុំជម្រះច្រានចោលសំណើសុំរបស់ ក.ស.ព.។

5. អង្គជំនុំជម្រះទទួលស្គាល់ថា ព័ត៌មានដែលស្ថិតក្រោមការការពាររួមទាំងឈ្មោះសាក្សី ហើយនឹងសក្ខីកម្មនៅក្នុងពេលធ្វើសវនាការអសាធារណៈនឹងត្រូវដកស្រង់នៅក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោល។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឲ្យដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២ ទាំងអស់ក្នុងលក្ខណៈសម្ងាត់ត្រឹមកាលបរិច្ឆេទដូចបានកំណត់នាពេលមុនរួចហើយ ពោលគឺ នៅត្រឹម<u>ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៧</u> ដោយសំណៅមានការកោសលុបត្រូវដាក់ជូននៅត្រឹម<u>ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៧</u>។ ប្រសិនបើបានទទួលបានព័ត៌មានថ្មីៗពី ស.ច.ស.អ. ភ្លាមនោះ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាលើភាពចាំបាច់ក្នុងការរក្សាការសម្ងាត់នៃសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលឡើងវិញ។

6. អនុស្សរណៈនេះជាចម្លើយតបផ្លូវការពីអង្គជំនុំជម្រះសាលាដំបូងទៅនឹងឯកសារ E319/35/7 និងឯកសារ E319/35/10។